**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកៅស៊ូ**

ថ្ងៃ.ចន្ទ..៧កើត..ខែ..មិគសិរ......ឆ្នាំជូត..ទោស័ក ព.ស.២៥៦៤

លេខ: ៩២៥ អក.ទន

រាជធានីភ្នំពេញ ថ្ងៃទី......២១......ខែ..ធ្នូ..................ឆ្នាំ២០២០

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖-របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០២០...........ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូ ប្រចាំខែវិច្ឆិកាឆ្នាំ២០២០ ......................................................................ចំនួន០២ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តសម្រាប់ចុះក្នុងរបាយការណ៍របស់ក្រសួងក្នុងខែធ្នូដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០១ ៦៩៩ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៨៩ ៨៣៧ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១១ ៨៦៣ហិកតា ស្មើនឹង២៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន៤៣ ៦១២តោន កើនឡើងចំនួន៨ ៦៧៤តោន ស្មើនឹង២៥% ធៀបនឹងខែមុននិងបានកើនឡើងចំនួន៨ ៩៧៥ ស្មើនឹង២៦%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ ផលិតផលជ័រកៅស៊ូមកដល់ខែនេះមានចំនួន២៩១ ៣២៧តោន បានកើនឡើងចំនួន៥៣ ០៧៤តោន ស្មើនឹង២២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងខែមានចំនួន៤២ ៦៦៧តោន បានកើនឡើងចំនួន៩ ៦២៤តោន ស្មើនឹង២៩%ធៀបនឹងខែមុន និងបានកើនឡើងចំនួន៩ ០៨៦តោនស្មើនឹង២៧%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ បរិមាណបញ្ចេញលក់មកដល់ខែនេះមានចំនួន២៨៥ ៥៨៩តោន បានកើនឡើងចំនួន៥១ ៨២០តោន ស្មើនឹង២២%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ៥១៤ដុល្លារ/តោន បានកើនឡើងចំនួន៨១ដុល្លារ/តោនស្មើនឹង ៥,៧%ធៀបនឹងខែមុន និងបានកើនឡើង១៨៧ដុល្លារ/តោនស្មើនឹង១៤%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ តម្លៃលក់កៅស៊ូមធ្យមគិតដល់ខែនេះថ្លៃ១ ៣៤១ដុល្លារ/តោន បានកើនឡើងចំនួន១២ដុល្លារ/តោនស្មើនឹង០,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៥ ១៥០-៥ ៩៥០៛/គ.ក្រ(បានកើនឡើងចំនួន៧១៣៛/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ២ ២៥០-២ ៩២៥៛/គ.ក្រ បានកើនឡើងចំនួន១៩១៛/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"

- ឯកសារ

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No. 6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២០
# និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០ នេះអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារជាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០១ ៦៩៩ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៨៩ ៨៣៧ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១១ ៨៦៣ហិកតា ស្មើនឹង២៨%។

#### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ មានចំនួន៤៣ ៦១២តោន បានកើនឡើងចំនួន៨ ៦៧៤តោនស្មើនឹង២៥%ធៀបនិងខែមុននឹងបានកើនឡើងចំនួន៨ ៩៧៥តោនស្មើនឹង២៦%ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

-ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែវិច្ឆិកា ឆ្នាំ២០២០ សម្រេចបានចំនួន២៩១ ៣២៧តោនបានកើនឡើងចំនួន៥៣ ០៧៤តោន ស្មើនឹង២២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០២០ មានចំនួន៤២ ៦៦៧តោន បានកើនឡើងចំនួន៩ ៦២៤តោន ស្មើនឹង២៩%ធៀបនឹងខែមុននិងបានកើនឡើងចំនួន៩ ០៨៦តោនស្មើនឹង២៧%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសរុបគិតមកដល់ខែវិច្ឆិកា ឆ្នាំ២០២០ សម្រេចបានចំនួន២៨៥ ៥៨៩តោន បានកើនឡើងចំនួន៥១ ៨២០តោន ស្មើនឹង២២%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់មធ្យមជ័រកៅស៊ូក្នុងខែវិច្ឆិកា ឆ្នាំ២០២០ គឺ១ ៥១៤ដុល្លារ/តោន បានកើនឡើងចំនួន៨១ដុល្លារ/តោន ស្មើនឹង ៥,៧%ធៀបនឹងខែមុន និងបានកើនឡើងចំនួន១៨៧ដុល្លារ/តោនស្មើនឹង១៤%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់ជ័រកៅស៊ូគិតជាមធ្យមមកដល់ខែវិច្ឆិកា ឆ្នាំ២០២០ គឺ១ ៣៤១ ដុល្លារ/តោន បានកើនឡើងចំនួន១២ ដុល្លារ/តោន ស្មើនឹង០,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៥ ១៥០-៥ ៩៥០ រ/គ.ក្រ(បានកើនឡើងចំនួន៧១៣រ/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ២ ២៥០-២ ៩២៥រ/គ.ក្រ បានកើនឡើងចំនួន១៩១រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្ត និងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ នៅស្រុកសៀមបូ ខេត្តស្ទឹងត្រែង
- ចុះតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ នៅខេត្តព្រះវិហារ
- ចូលរួមពិនិត្យ និងកែសម្រួលស្តីពីការសិក្សាលក្ខណៈសម្បត្តិចម្ការកៅស៊ូគ្រួសារនៅខេត្តមណ្ឌលគីរី ក្នុងនោះរួមមាន៖ ១.វិសាលភាពនៃការសិក្សា ២.វិធីសាស្ត្រនៃការសិក្សា ៣.លទ្ធផលនៃការសិក្សា ៤.សេចក្តីសន្និដ្ឋាន និងអនុសាសន៍
- បញ្ចូលទិន្នន័យការចំណាយសរុបទៅតាមសកម្មភាពនីមួយៗ របស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ សម្រាប់ឆ្នាំ២០២០ ក្នុងនោះរួមមាន៖ ១.បណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារ ២.ពង្រឹងសហគមន៍ កសិកម្មកៅស៊ូគ្រួសារ ៣.ចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ និង ៤.សិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូ ដល់មន្ត្រីបង្គោល
- ចុះបំពេញបេសកកម្ម ជាមួយអង្គការ OXFAM ប្រចាំកម្ពុជាទៅតាមបណ្តាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ចំនួន៤គឺ ១.ក្រុមហ៊ុនតៃនិញសៀមរាបអភិវឌ្ឍន៍កៅស៊ូ ២.ក្រុមហ៊ុនសំរោងរ៉ាប់បើអ៊ិនដាស្ទ្រៀល ភីធី អ៊ី អិលធីឌី ៣.ក្រុមហ៊ុនបៀនហៀក អិនវេសមេន ខូអិលធីឌី និង ៤.ក្រុមហ៊ុនសម្បត្តិផ្លែធីណឹមខូអិលធីឌី ដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមក និងស្វែងរកកិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍វិស័យកៅស៊ូ នៅកម្ពុជាប្រកបដោយនិរន្តភាព
- ចុះតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ នៅខេត្តព្រះវិហារ
- ចុះពិនិត្យស្ថាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដែលបានទទួលលិខិតអនុញ្ញាតពីអគ្គនាយកដ្ឋានកៅស៊ូ នៅខេត្តក្រចេះ និងខេត្តរតនគីរី
- បានពិនិត្យ ពិភាក្សា កែសម្រួលខ្លឹមសារនិងតួលេខ លើរបាយការណ៍ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម ដែលភាគីវៀតណាមបានផ្ញើមកលើកចុងក្រោយ
- បានរៀបចំកែសម្រួល Directory បន្ត
- ប្រជុំពិនិត្យវឌ្ឍនភាពនិងប្រមូលធាតុចូលពីនាយកដ្ឋានជំនាញ សម្រាប់ដាក់បញ្ចូលនៅក្នុង Website របស់អគ្គនាយកដ្ឋានកៅស៊ូ
- បានប្រជុំពិនិត្យសម្រេចព្រឹត្តិបត្រកៅស៊ូធម្មជាតិខែកញ្ញា វឌ្ឍនភាពខែតុលា និងលើកទិសដៅ ខែវិច្ឆិកា ឆ្នាំ២០២០

២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិការរហូតមកដល់ខែវិច្ឆិកានេះមានចំនួន៩៦៨ ៦៦៨ ៦១៨រៀល ស្មើនឹង៧៤,០៦ភាគរយ នៃផែនការ ក្រោយធ្វើវិចារណកម្មការចំណាយថវិកាទាំងពីរលើកមានចំនួន១ ៣០៧ ៩០០ ០០០រៀល (សម្រាប់ក្នុងខែវិច្ឆិកាពុំបានអនុវត្តទេ)។

២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលរហូតមកដល់ខែវិច្ឆិកានេះ មានចំនួន៨៦៩ ៣៧៤ ៦៣៧រៀល ស្មើនឹង៥៥,៥២ភាគរយនៃផែនការ សម្រាប់ក្នុងខែវិច្ឆិកា ការប្រមូលចំណូលមានចំនួន១០៣ ៩២៥ ៨១០រៀល។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ
- ចុះសម្របសម្រួលរៀបចំសិក្ខាសាលាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចជាមួយអង្គការ OXFAM
- បន្តសហការជាមួយអង្គការ WWF រៀបចំវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ រៀបចំ Leaflates, រៀបចំ Demo, រៀបចំ Vedeo បច្ចេកទេស និងពង្រឹងសហគមន៍នៅខេត្តមណ្ឌលគីរី
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២០
- បន្តរៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បន្តខិតខំផ្សព្វផ្សាយតម្លៃជ័រកៅស៊ូធម្មជាតិ នៅលើទីផ្សារក្នុងស្រុកនិងអន្តរជាតិតាមបណ្តាញសង្គម (ហ្វេសប៊ុក)ឲ្យបានដល់កសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូ
- បន្តសិក្សាស្រាវជ្រាវផ្សព្វផ្សាយពត៌មានអំពីការផ្គត់ផ្គង់ តម្រូវការ ការប្រើប្រាស់កៅស៊ូធម្មជាតិនិងនិន្នាការតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តតាមដានលើវឌ្ឍនភាព នៃកិច្ចសហប្រត្តិបត្តិការជាមួយបណ្តាប្រទេសជាដៃគូរ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូបានប្រគល់អោយ។

ថ្ងៃ៩ខ្ទ ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២០

**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

យួន_ផល្លា

**បានឃើញនិងឯកភាព**

**ឯ.ឧ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

ចាន់_វឌ្ឍនា

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០២០

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៩ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចៀរជ័រ | ថែទាំ | សរុប | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | | | | | | | | | | | | | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 520 | 100 | 620 | 39 | 383 | 50 | 250 | 158 | 86 | 441 | 50 | 163 | 0 | 0 | 22 | 34 | 0 | 0 | 48 | 123 | 58 | 15 | 0 | 0 | -87 | -35 | 436 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 11.287 | 2.048 | 13.335 | 1.819 | 13.997 | 1.926 | 14.514 | 1.093 | 1.890 | 15.065 | 1.789 | 15.029 | 0 | 0 | 444 | 31 | 700 | 64 | 71 | 4 | 1.068 | 8 | -137 | -7 | 515 | 4 | 1.129 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.179 | 1.262 | 2.440 | 194 | 1.464 | 210 | 1.491 | 21 | 204 | 1.288 | 105 | 1.134 | 0 | 0 | 38 | 23 | -21 | -17 | 10 | 5 | -176 | -12 | -105 | -50 | -357 | -24 | 175 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.092 | 2.331 | 8.423 | 515 | 3.896 | 551 | 4.087 | 618 | 580 | 4.410 | 370 | 4.252 | 367 | 5 | 129 | 29 | -132 | -26 | 65 | 13 | 514 | 13 | -181 | -33 | 165 | 4 | 776 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 60 | 295 | - | 233 | 47 | 67 | 408 | 42 | 395 | 0 | 0 | 19 | 38 | 0 | 0 | 7 | 11 | 113 | 38 | 42 | 100 | 162 | 69 | 59 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស៍ លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | 641 | 3.847 | 624 | 4.175 | 1.911 | 654 | 3.827 | 441 | 4.508 | 0 | 0 | 289 | 79 | -219 | -33 | 14 | 2 | -20 | -1 | -183 | -29 | 333 | 8 | 1.230 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 3.908 | 278 | 4.186 | 605 | 3.191 | 525 | 3.677 | 706 | 420 | 2.725 | 120 | 2.576 | 0 | 0 | 270 | 180 | 120 | 100 | -185 | -31 | -466 | -15 | -405 | -77 | -1.101 | -30 | 855 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 201 | 1.621 | - | 1.177 | 613 | 138 | 1.391 | 130 | 1.388 | 0 | 0 | 34 | 33 | -40 | -24 | -64 | -32 | -230 | -14 | 130 | 100 | 211 | 18 | 616 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+រមាសហែក) | 1.918 | 1.119 | 3.037 | 151 | 1.125 | 118 | 852 | 380 | 89 | 828 | 70 | 794 | 0 | 0 | 9 | 11 | -35 | -33 | -61 | -41 | -297 | -26 | -48 | -40 | -58 | -7 | 414 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4.097 | 159 | 4.256 | 612 | 5.535 | 777 | 6.312 | 550 | 584 | 4.944 | 1.050 | 4.649 | 0 | 0 | 20 | 4 | 1.050 | 100 | -28 | -5 | -591 | -11 | 273 | 35 | -1.663 | -26 | 845 |
| | សរុប ក | 36.794 | 11.361 | 48.154 | 4.837 | 35.354 | 4.781 | 36.769 | 6.097 | 4.712 | 35.327 | 4.167 | 34.889 | 367 | 1 | 1.274 | 37 | 1.424 | 52 | -125 | -3 | -26 | 0 | -614 | -13 | -1.880 | -5 | 6.536 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 104.999 | 87.443 | 192.442 | 12.100 | 82.400 | 11.500 | 78.800 | 3.653 | 13.500 | 103.200 | 13.000 | 100.600 | 0 | 0 | 1.500 | 13 | 2.000 | 18 | 1400 | 12 | 20.800 | 25 | 1.500 | 13 | 21.800 | 28 | 6.253 |
| | សរុបI=ក+ខ | 141.793 | 98.804 | 240.596 | 16.937 | 117.754 | 16.281 | 115.569 | 9.750 | 18.212 | 138.527 | 17.167 | 135.489 | 367 | 0 | 2.774 | 18 | 3.424 | 25 | 1275 | 8 | 20.774 | 18 | 886 | 5 | 19.920 | 17 | 12.789 |
| | II. កៅស៊ូគ្រួសារ | 148.044 | 13.059 | 161.103 | 17.700 | 120.500 | 17.300 | 118.200 | 7.076 | 25.400 | 152.800 | 25.500 | 150.100 | 0 | 0 | 5.900 | 30 | 6.200 | 32 | 7700 | 44 | 32.300 | 27 | 8.200 | 47 | 31.900 | 27 | 9.776 |
| | សរុបរួមI+II | 289.837 | 111.863 | 401.699 | 34.637 | 238.254 | 33.581 | 233.769 | 16.826 | 43.612 | 291.327 | 42.667 | 285.589 | 367 | 0 | 8.674 | 25 | 9.624 | 29 | 8975 | 26 | 53.074 | 22 | 9.086 | 27 | 51.820 | 22 | 22.565 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤០១ ៦៩៩ ហត ( ផ្ទៃដីចៀរជ័រ ២៨៩ ៨៣៧ ហត ថែទាំ ១១១ ៨៦៣ហត) ។

(២) ផលិតផលសរុបមានចំនួន៤៣ ៦១២ តោន បានកើនឡើងចំនួន៨ ៦៧៤ តោន(២៥%) ធៀបនិងខែមុននឹងបានកើនឡើងចំនួន៨ ៩៧៥តោន(២៦%)ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០២០ ផលិតផលសរុបមានចំនួន២៩១ ៣២៧ តោន បានកើនឡើងចំនួន៥៣ ០៧៤តោន ( ២២%)ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ចេញលក់សរុបមានចំនួន៤២ ៦៦៧តោន បានកើនឡើងចំនួន៩ ២៦៤ តោន (២៩%)ធៀបនិងខែមុននឹងបានកើនឡើងចំនួន៩ ០៨៦តោន(២៧%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០២០ ការបញ្ចេញលក់សរុបមានចំនួន២៨៥ ៥៨៩តោន បានកើនឡើងចំនួន៥១ ៨២០តោន (២២%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦)សន្និធិចុងគ្រាមានចំនួន២២ ៥៦៥ តោន

ថ្ងៃច័ន្ទ ៧កើត ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២០
អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

**អគ្គនាយកដ្ឋានកៅស៊ូ**
**នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែវិច្ឆិកា ឆ្នាំ២០២០

**តារាងទី២**

| ល.រ | ចម្ការកៅស៊ូ | វិច្ឆិកា ២០១៩ | | | | | | វិច្ឆិកា ២០២០ | | | | | | ធៀបខែមុន | | | | ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ | | ថ្លៃមធ្យម | | បរិមាណ | | | | ថ្លៃមធ្យម | | | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | | | | | | | | | | | | | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 50 | 250 | 65.000 | 316.500 | 1.300 | 1.266 | 50 | 163 | 66.500 | 198.914 | 1.330 | 1.217 | 0 | 0,0 | 130 | 10,8 | 0 | 0 | -87 | -35 | 30 | 2 | -49 | -4 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 1.926 | 14.514 | 2.565.374 | 19.528.436 | 1.332 | 1.345 | 1.789 | 15.029 | 2.687.919 | 19.830.901 | 1.503 | 1.320 | 700 | 64,3 | 9 | 0,6 | -137 | -7 | 515 | 4 | 171 | 13 | -26 | -2 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 210 | 1.491 | 280.770 | 1.933.650 | 1.337 | 1.297 | 105 | 1.134 | 173.250 | 1.448.949 | 1.650 | 1.278 | -21 | -16,7 | 347 | 26,6 | -105 | -50 | -357 | -24 | 313 | 23 | -19 | -1 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 551 | 4.087 | 739.148 | 5.644.798 | 1.341 | 1.381 | 370 | 4.252 | 603.800 | 5.977.644 | 1.632 | 1.406 | -132 | -26,2 | 112 | 7,3 | -181 | -33 | 165 | 4 | 291 | 22 | 25 | 2 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | | 233 | | 249.994 | 0 | 1.072 | 42 | 395 | 59.760 | 445.262 | 1.423 | 1.126 | 0 | 0,0 | 193 | 15,7 | 42 | 100 | 162 | 69 | 1.423 | 100 | 55 | 5 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស៍ លីមីធីត(ស្នួល) | 624 | 4.175 | 833.670 | 5.450.640 | 1.336 | 1.305 | 441 | 4.508 | 630.210 | 5.846.778 | 1.429 | 1.297 | -219 | -33,2 | 110 | 8,3 | -183 | -29 | 333 | 8 | 93 | 7 | -9 | -1 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេសិនណល | 525 | 3.677 | 702.450 | 4.874.115 | 1.338 | 1.326 | 120 | 2.576 | 165.600 | 3.502.204 | 1.380 | 1.360 | 120 | 100,0 | 1.380 | 100,0 | -405 | -77 | -1.101 | -30 | 42 | 3 | 34 | 3 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | | 1.177 | | 1.457.234 | 0 | 1.238 | 130 | 1.388 | 173.400 | 1.710.725 | 1.334 | 1.232 | -40 | -23,5 | -107 | -7,4 | 130 | 100 | 211 | 18 | 1.334 | 100 | -6 | 0 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 118 | 852 | 137.320 | 1.057.436 | 1.168 | 1.241 | 70 | 794 | 93.600 | 972.274 | 1.337 | 1.225 | -35 | -33,3 | -97 | -6,8 | -48 | -40 | -58 | -7 | 169 | 15 | -17 | -1 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 777 | 6.312 | 1.019.340 | 8.283.150 | 1.312 | 1.312 | 1.050 | 4.649 | 1.654.800 | 6.293.610 | 1.576 | 1.354 | 1.050 | 100,0 | 1.576 | 100,0 | 273 | 35 | -1.663 | -26 | 264 | 20 | 42 | 3 |
| | **សរុប ក** | **4.781** | **36.769** | **6.343.072** | **48.795.953** | **1.327** | **1.327** | **4.167** | **34.889** | **6.308.839** | **46.227.261** | **1.514** | **1.325** | **1.424** | **51,9** | **81** | **5,7** | **-614** | **-13** | **-1.880** | **-5** | **187** | **14** | **-2** | **0** |
| ខ | កៅស៊ូសម្បទានដីសេដ្ឋកិច្ច | 11.500 | 78.800 | 15.257.589 | 104.784.321 | 1.327 | 1.330 | 13.000 | 100.600 | 19.682.382 | 134.454.800 | 1.514 | 1.337 | 2.000 | 18,2 | 81 | 5,7 | 1.500 | 13 | 21.800 | 28 | 187 | 14 | 7 | 1 |
| | **សរុបI=ក+ខ** | 16.281 | 115.569 | 21.600.661 | 153.580.274 | 1.327 | 1.329 | 17.167 | 135.489 | 25.991.222 | 180.682.061 | 1.514 | 1.334 | 3.424 | 24,9 | 81 | 5,7 | 886 | 5 | 19.920 | 17 | 187 | 14 | 5 | 0 |
| | II. កៅស៊ូគ្រួសារ | 17.300 | 118.200 | 22.952.721 | 157.153.489 | 1.327 | 1.330 | 25.500 | 150.100 | 38.607.750 | 202.413.837 | 1.514 | 1.349 | 6.200 | 32,1 | 81 | 5,7 | 8.200 | 47 | 31.900 | 27 | 187 | 14 | 19 | 1 |
| | **សរុបI+II** | **33.581** | **233.769** | **44.553.382** | **310.733.764** | **1.327** | **1.329** | **42.667** | **285.589** | **64.598.972** | **383.095.898** | **1.514** | **1.341** | **9.624** | **29,1** | **81** | **5,7** | **9.086** | **27** | **51.820** | **22** | **187** | **14** | **12** | **0,9** |

**បញ្ជាក់៖**

១. ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន៤២ ៦៦៧តោន បានកើនឡើងចំនួន៩ ៦២៤តោន(=+២៩,១%)ធៀបនឹងខែមុន និងបានកើនឡើងចំនួន៩ ០៨៦តោន(=+២៧%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ថ្លៃលក់មធ្យមគឺ១ ៥១៤USD$/តោន បានកើនឡើងចំនួន៨១USD$/តោន (=៥,៧%) ធៀបនឹងខែមុន និងបានកើនឡើងចំនួន១៨៧USD$/តោន (=១៤%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន២៨៥ ៥៨៩តោន បានកើនឡើង៥១ ៨២០តោន (=+២២%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០ ថ្លៃលក់មធ្យមគឺ១ ៣៤១USD$/តោន បានកើនឡើងចំនួន១២USD$/តោន (=០,៩%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

**បានឃើញ និងឯកភាព**
**ឧ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**យុន ភក្កដា**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ**

**ហ៊ិន-សាផន**

ថ្ងៃចន្ទ ៧កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២០
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

# ថ្លៃប្រមូលទិញជ័រកៅស៊ូពីកសិករកៅស៊ូគ្រួសារ

*ខែវិច្ឆិកា ឆ្នាំ២០២០*

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | ថ្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/ គ.ក្រ | ធៀប សប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | ៛/គ.ក្រ |
| ១ | កំពង់ចាម | 5.150 | 1,27 | ↑ 350 | 2.400 | 0,59 | ↑ 100 | 5.500 | 1,36 | ↑ 350 | 2.500 | 0,62 | ↑ 100 | 5.500 | 1,36 | → 0 | 2.700 | 0,67 | ↑ 200 | 5.500 | 1,36 | → 0 | 2.700 | 0,67 | → 0 | 5.413 | 2575 |
| ២ | ត្បូងឃ្មុំ | 5.800 | 1,43 | ↑ 200 | 2.400 | 0,59 | ↑ 100 | 5.500 | 1,36 | ↓ 300 | 2.200 | 0,54 | ↓ 200 | 5.500 | 1,36 | → 0 | 2.200 | 0,54 | → 0 | 5.500 | 1,36 | → 0 | 2.200 | 0,54 | → 0 | 5.575 | 2250 |
| ៣ | កំពង់ធំ | 5.600 | 1,38 | ↑ 800 | 2.500 | 0,62 | ↑ 200 | 5.600 | 1,38 | → 0 | 2.500 | 0,62 | → 0 | 5.500 | 1,36 | ↓ 100 | 2.300 | 0,57 | ↓ 200 | 5.500 | 1,36 | → 0 | 2.300 | 0,57 | → 0 | 5.550 | 2400 |
| ៤ | រតនគិរី | 4.400 | 1,08 | ↓ 200 | 2.400 | 0,59 | ↓ 200 | 5.400 | 1,33 | ↑ 1.000 | 2.600 | 0,64 | ↑ 200 | 5.400 | 1,33 | → 0 | 2.600 | 0,64 | → 0 | 5.400 | 1,33 | → 0 | 2.600 | 0,64 | → 0 | 5.150 | 2550 |
| ៥ | ក្រចេះ | 6.000 | 1,48 | ↑ 400 | 3.000 | 0,74 | ↑ 300 | 6.000 | 1,48 | → 0 | 3.000 | 0,74 | → 0 | 5.900 | 1,46 | ↓ 100 | 2.850 | 0,70 | ↓ 150 | 5.900 | 1,46 | → 0 | 2.850 | 0,70 | → 0 | 5.950 | 2925 |
| ៦ | មណ្ឌលគិរី | | | | 2.700 | 0,67 | → 0 | | | | 2.600 | 0,64 | ↓ 100 | | | | 2.600 | 0,64 | → 0 | | | | 2.600 | 0,64 | → 0 | | 2625 |
| តម្លៃមធ្យម | | 5.390 | 1,33 | ↑ 310 | 2.567 | 0,63 | ↑ 83 | 5.600 | 1,38 | ↑ 210 | 2.567 | 0,63 | → 0 | 5.560 | 1,37 | ↓ 40 | 2.542 | 0,63 | ↓ 25 | 5.560 | 1,37 | → 0 | 2.542 | 0,63 | → 0 | 5.528 | 2.554 |
| អត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា | | | 4.060 | | | | | | 4.050 | | | | | | 4.050 | | | | | | 4.045 | | | | | | |

ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ ថ្លៃ៥១៥០-៥៩៥០៛/គ.ក្រ (មានការកើនឡើងចំនួន៧១៣៛/គ.ក្រ ធៀបខែមុន) និងជ័រកក ថ្លៃ២២៥០-២៩២៥៛/គ/ក្រ (មានការកើនឡើងចំនួន១៩១៛/គ.ក្រ ធៀបខែមុន) អាស្រ័យតាមតំបន់។

បញ្ជាក់៖

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*
*ទឹកជ័រ: គិតជាស្ងួត (DRC)*
*ជ័រកក: DRC ≅ 50%*

ថ្ងៃ ច័ន្ទ ៧កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២០
អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន កក្កដា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន